ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 04 / 01 / 2013
ម៉ោង (Time/Heure): 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

## <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣៦

រៀបចំដោយ: ឌុច ផារី និង Roger PHILLIPS

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក ដាវ អានសាន, លោក Matteo CRIPPA, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វ៉េង ហ៊ាត់, លោក Tarik ABDULHAK |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន, អៀង សារី (ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZI, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ, លោកស្រី ទី ស្រីនណា, លោក ហុង គឹមសួន, លោក វ៉េន ពៅ, លោកស្រី ស៊ិន សុវ៉ន, លោកស្រី Isabelle DURAND, លោកស្រី Martine JACQUIN |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក គឹម វ៉ាន់ឌី (TCCP-59), លោក ហ៊ុន ឈុនលី (TCW-247) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុខ្មារី, លោក នូ មនោរ, លោកស្រី Seynabou Johanne Diop |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០៣ | បញ្ចប់ម៉ោង៖ ១៦.០៤ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៨ | បញ្ចប់ម៉ោង៖ ១០.៣៨ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៣ | បញ្ចប់ម៉ោង៖ ១៣.៣១ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤២ | បញ្ចប់ម៉ោង៖ ១៥.០៦ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខ/រដ្ឋប្បវេណី | ៩.០៧ | ៩.០៩ |
| ការកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី | មេធាវីការពារក្តី អៀង សារី | ៩.០៩ | ៩.២៣ |
| ការបន្តស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី *(TCCP-59)* | សហមេធាវីនាំមុខ/រដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញា | ៩.២៤<br>៩.៥០ | ៩.៤៩<br>១០.០៨ |
| ការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី *(TCCP-59* | អង្គជំនុំជម្រះ | ១០.១០ | ១០.១៧ |
| ការស្តាប់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី TCW-247 | អង្គជំនុំជម្រះ | ១០.៤០ | ១០.៤៦ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា | ១០.៤៦ | ១៦.០២ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី នួន ជា | ១២.០១ | ១២.០៣ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការស្នើសុំទទួលស្គាល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ**

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាតិស្នើសុំឱ្យអង្គជំនុំជម្រះទទួលស្គាល់លោកស្រី Isabelle DURAND ជាមេធាវីអន្តរជាតិតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រី Isabelle DURAND ជាសមាជិកគណៈមេធាវីទីក្រុង Toulouse ប្រទេសបារាំង (Toulouse Bar Association) ហើយត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។ អង្គជំនុំជម្រះទទួលស្គាល់លោកស្រីមេធាវី Isabelle DURAND ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះ ហើយចាប់ពីពេលនេះទៅ លោកស្រីមានសិទ្ធិនិងបុព្វសិទ្ធិដូចមេធាវីជាតិ ។

**ការកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី**

មេធាវីការពារក្តីរបស់លោក អៀង សារី បានធ្វើសំណើមួយចំនួនទាក់ទងនឹងស្ថានភាពសុខភាពរបស់របស់កូនក្តីខ្លួន ។ ទីមួយ៖ មេធាវីស្នើសុំឱ្យលោក អៀង សារី បានតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់រយៈពេលពេញមួយថ្ងៃ ដោយសារលោក អៀង សារី អស់កម្លាំងខ្លាំង និងមិនអាចអង្គុយបានយូរ ។ ទីពីរ៖ មេធាវីស្នើសុំឱ្យអង្គជំនុំជម្រះចាត់តាំងអ្នកជំនាញដើម្បីវាយតម្លៃអំពីស្ថានភាពលោក អៀង សារី ថាតើគាត់មានសម្បទាបញ្ញាស្មារតីគ្រប់គ្រាន់ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីដែរឬទេ ។ មេធាវីក៏បានស្នើសុំឱ្យមានការវាយតម្លៃនូវស្ថានភាពបញ្ញាស្មារតីកូនក្តីខ្លួនប្រចាំថ្ងៃផងដែរ ។ ទីបី៖ មេធាវីក៏បានស្នើសុំការបញ្ជាក់ផងដែរ ថាតើអ្នកគ្រប់គ្រងសំណុំរឿងរបស់ខ្លួនត្រូវទទួលខុសត្រូវក្នុងការដាស់ជនជាប់ចោទដែរឬទេ នៅពេលគាត់ដេកលក់ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីនោះ ។

**ការបន្តស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី (TCCP-59)**

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តការតាំងសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា ។ មេធាវីការពារក្តីទាំងបីក្រុមមិនមានសំណួរត្រូវចោទសួរដល់

ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំរបស់ជនជាប់ចោទ។

**<u>ការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី</u>** <u>(TCCP-59)</u>

ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី អាននូវសេចក្តីថ្លែងការ ដែលបង្ហាញពីទុក្ខសោក និងការឈឺចាប់ដែលគាត់បានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

**<u>ការស្តាប់សក្ខីកម្មរបស់សាក្សី ហ៊ុន ឈុនលី</u>** <u>(TCW-247)</u>

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់សាក្សី បន្ទាប់មកការតាំងសំណួរបន្តដោយសហព្រះរាជអាជ្ញា។ មេធាវីការពារក្តីទាំងបីក្រុមមិនមានសំណួរសម្រាប់សួរដល់សាក្សីនោះទេ ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|
| E3/3971 | D22/1352 | 00526163-00526174<br>00866005-00866013<br>00867506-00867519 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គីម វ៉ាន់ឌី KIM Vanndy 08-VU-01538<br>Civil party application of KIM Vanndy 08-VU-01538<br>Constitution de partie civile de KIM VANNDY 08-VU-01538 | P | 00526168 | 00866008 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3351 | D313/1.2.8 | 00678744-00678942<br>00369669-00369820<br>00700301-00700309 | សៀវភៅនិពន្ធដោយលោក HUN Chunly មានចំណងជើងថា "ជីវិតគ្រូពេទ្យម្នាក់ក្នុងរបបខ្មែរក្រហម"<br>Book by HUN Chunly entitled "The Life of a Physician under the Khmer Rouge Regime"<br>Livre de HUN Chunly intitulé "The Life of a Physician under the Khmer Rouge Regime" | P | 00678758, 00678761-62, 00678763, 00678769, 00678759, 00678762, 00678813, 00678765, 00678768, 00678758, 00678774, 00678777, 00678779, 00678778-79, 00678782, 00678789, 00678793, 00678815, 00678842, 00678846, 00678804, 00678836, 00678822, 00678828, 00678865 | 00369685, 00369689, 00369682, 00369721-22, 00369686, 00369688, 00369689, 00369693, 00369695, 00369696, 00369699, 00369705, 00369707, 00369723, 00369741, 00369744, 00369716, 00369736, 00369727, 00369731, 00369758 | |
| E3/3972 | D108/26.104 | 00086927-00086933<br>00837604-00837613<br>00864725-00864733 | ឧបសម្ព័ន្ធ ១០៤៖ បញ្ជីរាយការណ៍ប្រចាំខែ ៩ ឆ្នាំ ១៩៧៧ អំពីអ្នកទោសមកពីភូមិភាគពាយ័ព្យ និងភូមិភាគបស្ចឹម<br>Annex 104: S-21 Prisoner List containing names of prisoners from the NorthwestZone and the WesternZone<br>Annexe 104: Liste mensuelle des prisonniers originaires des zones Nord-ouest et Est (septembre 1977) | P | 00086931 | 00837610 | 00864730-31 |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យជនជាប់ចោទ នួន ជា ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី(TCCP-59) និងសាក្សី ហ៊ុន ឈុនលី TCW-247 ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំសាក្សី ហ៊ុន ឈុនលី ត្រឡប់មកកាន់សាលសវនាការវិញនៅព្រឹកថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ខៀវ សំផន និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ (ចំពោះជនជាប់ចោទ អៀង សារី ត្រូវនាំមកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ) ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ សុក្រ ទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១២

ក្រឡាបញ្ជី [stamp] ក្រឡាបញ្ជី

ឌុច ឆារី Roger PHILLIPS